អនុវត្ត

# គោលការណ៍មិនដាក់ទណ្ឌកម្ម

## ដើម្បីការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ការសិក្សាមួយស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មនៅអាស៊ីអាគ្នេយ៍ ដែលពិនិត្យមើលច្បាប់ គោលនយោបាយ និងការប្រតិបត្តិ ដាក់ចេញនូវអនុសាសន៍ខាងក្រោមដើម្បីការពារជនរងគ្រោះពីការដាក់ទណ្ឌកម្មនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ៖

## កិច្ចការពារនៅក្នុង ការកំណត់អត្តសញ្ញាណ និងការស៊ើបអង្កេត



១ កសាងសមត្ថភាពមន្ត្រីជួរមុខក្នុងការកំណត់អត្តសញ្ញាណជនដែលអាចគឺជាជនរងគ្រោះដោយអំពើជួញដូរក្នុងចំណោមជនដែលពួកគេបានជួបប្រាស្រ័យជាជនល្មើស

២ ពង្រឹងការយល់ដឹងអំពីការអនុវត្តច្បាប់លើវិធីសាស្ត្រគ្រប់គ្រងដែលជនល្មើសជួញដូរប្រើ និងផលប៉ះពាល់របស់វាលើជនរងគ្រោះ

៣ ជំនះលើការយល់ខុស និងការសន្មតអំពីជនរងគ្រោះដោយអំពើជួញដូរដែលមានលក្ខណៈ "ជាគំរូ" ឬ "សមជាជនរងគ្រោះ"

៤ ធានាឱ្យបានប្រាកដថាជនល្មើសដែលអាចជាជនរងគ្រោះដោយអំពើជួញដូរត្រូវបានបញ្ជូនទៅពិនិត្យចម្រាញ់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល

៥ ស៊ើបអង្កេតក្នុងលក្ខណៈសកម្មមុននូវទំនាក់ទំនងរវាងបទល្មើសរបស់ជនដែលអាចជាជនរងគ្រោះ-ជនល្មើស និងការប្រព្រឹត្តរបស់ជនដែលអាចជាជនជួញដូរ

## កិច្ចការពារពី ការចាប់ខ្លួន និងការចោទប្រកាន់



៦ ធានាឱ្យបានថាមន្ត្រីជួរមុខយល់ពីផលប៉ះពាល់នៃការចាប់ខ្លួនលើជនរងគ្រោះដោយអំពើជួញដូរ និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរ

៧ ធានាឱ្យបានថាមន្ត្រីជួរមុខយល់ដឹងពីធន្ធានុសិទ្ធិរបស់ខ្លួន និងរបៀបប្រើធន្ធានុសិទ្ធិទាំងនោះ

៨ ជំរុញលើកទឹកចិត្តអ្នកអនុវត្តច្បាប់ឱ្យអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម

៩ ធានាឱ្យបានថាមន្ត្រីដែលធ្វើការចាប់ខ្លួនយល់ពីកាតព្វកិច្ចរបស់ពួកគេចំពោះជនដែលត្រូវបានចាប់ខ្លួន

## កិច្ចការពារពី ការកាត់ទោស



១០ ធ្វើវិសោធនកម្មច្បាប់ដើម្បីកាត់បន្ថយហានិភ័យនៃការកាត់ទោសមិនត្រឹមត្រូវលើជនរងគ្រោះដោយអំពើជួញដូរ

១១ ធានាឱ្យបានប្រាកដថារាល់សេចក្តីសម្រេចណាមួយក្នុងការកាត់ទោសជនរងគ្រោះដោយអំពើជួញដូរ គឺត្រូវបានធ្វើតែបន្ទាប់ពីកិច្ចដំណើរការកំណត់អត្តសញ្ញាណជាផ្លូវការ ហើយសេចក្តីសម្រេចនេះត្រូវបានពន្យល់យ៉ាងច្បាស់លាស់

១២ បញ្ជាក់ពីទំនាក់ទំនងរវាងស្ថានភាពជនរងគ្រោះ និងការមិនកាត់ទោស

១៣ ធានាឱ្យបានប្រាកដថាព្រះរាជអាជ្ញាយល់ពីធន្ធានុសិទ្ធិរបស់ខ្លួន និងរបៀបប្រើធន្ធានុសិទ្ធិទាំងនោះ

១៤ ផ្តល់ការបណ្តុះបណ្តាលស្តីពីការប្រឆាំងការជួញដូរដល់ព្រះរាជអាជ្ញា ជាពិសេសព្រះរាជអាជ្ញាដែលមានឯកទេសខាងការកាត់ទោសបទល្មើសដែលជនរងគ្រោះដោយអំពើជួញដូរបានប្រព្រឹត្តជាទូទៅ

១៥ ពង្រឹងការយល់ដឹងអំពីភាពមិនសមស្របនៃការយល់ព្រមរបស់ជនរងគ្រោះក្នុងការជួញដូរមនុស្សក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម

## ការការពារក្តីតាមផ្លូវច្បាប់ ដើម្បីការពារជនរងគ្រោះ



១៦ រៀបចំសេចក្តីព្រាង ឬធ្វើវិសោធនកម្មបទប្បញ្ញត្តិច្បាប់ច្បាស់លាស់ ដើម្បីផ្តល់ប្រសិទ្ធភាពដល់ការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ដោយរាប់បញ្ចូលគ្រប់ជនរងគ្រោះទាំងអស់សម្រាប់បទល្មើសគ្រប់ប្រភេទ

១៧ ផ្តល់ការបណ្តុះបណ្តាល និងការណែនាំដល់អ្នកអនុវត្តពីរបៀបកំណត់ទំនាក់ទំនងរវាងបទល្មើសរបស់ជនរងគ្រោះ និងការជួញដូររបស់ពួកគេ

១៨ ផ្តល់ការបណ្តុះបណ្តាល និងការណែនាំដល់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ ស្តីពីការអនុវត្តការការពារក្តីទូទៅសម្រាប់ជនរងគ្រោះដែលបានប្រព្រឹត្តបទល្មើសដែលជាផលវិបាកផ្ទាល់ពីការត្រូវបានគេជួញដូរ

១៩ ធានាឱ្យបានប្រាកដថាបន្ទុកបង្ហាញភស្តុតាងស្ថិតនៅលើរដ្ឋ មិនមែនលើជនរងគ្រោះទេ

២០ ទប់ស្កាត់ការប្រើប្រាស់ខុសនៃគោលការណ៍មិនដាក់ទណ្ឌកម្ម

## កិច្ចការពារនៅក្នុង ការផ្តន្ទាទោស និងការដាក់ទោស



២១ ជំរុញការយល់ដឹងរបស់សមាជិកនៃស្ថាប័នតុលាការអំពីគោលការណ៍មិនដាក់ទណ្ឌកម្ម និងតួនាទីរបស់ពួកគេក្នុងការអនុវត្តគោលការណ៍នេះ

២២ ជៀសវាង ឬសម្រាលការដាក់ទោសចំពោះជនរងគ្រោះដោយអំពើជួញដូរដែលត្រូវបានផ្តន្ទាទោស

២៣ ពិចារណាអនុវត្តយុត្តិធម៌បែបស្តារនីតិសម្បទា ជាជាងយុត្តិធម៌បែបសងសឹកសម្រាប់ជនរងគ្រោះ-ជនល្មើស

២៤ ការពារជនរងគ្រោះដោយអំពើជួញដូរពីការទទួលទោសខាងរាងកាយ និងទោសប្រហារជីវិត

## ការកែតម្រូវក្រោយការផ្តន្ទាទោស សម្រាប់ជនរងគ្រោះ



២៥ ស្វែងរកឱកាសនៅក្នុងច្បាប់ដើម្បីលុបបំបាត់កំណត់ត្រាព្រហ្មទណ្ឌរបស់ជនរងគ្រោះដោយអំពើជួញដូរ

២៦ កំណត់ និងដោះស្រាយនូវឧបសគ្គនានាដែលជនរងគ្រោះដោយអំពើជួញដូរជួបប្រទះក្នុងការសុំឱ្យមានការលុបចោលការផ្តន្ទាទោស

សូមចូលមើលគេហទំព័រ aseanact.org ដើម្បីទាញយករបាយការណ៍ទាំងស្រុង